**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ...៣០៣៣...អពដ

ថ្ងៃព្រ.ហ ១៣ កើត ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ២០២០

# សេចក្តីណែនាំ
## ស្តីពី
## ការចុះបញ្ជីសកម្មភាពអាជីវកម្មដោយឡែករបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

អនុលោមតាមមាត្រា ៣ ថ្មី និងមាត្រា ១០១ នៃច្បាប់ស្តីពីសារពើពន្ធ និងប្រការ ៨ នៃប្រកាសលេខ ៤៦៤ សហវ.ប្រក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការណែនាំអនុវត្តកាតព្វកិច្ចសារពើពន្ធរបស់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល សមាគមឬអង្គការមិនមែនរដ្ឋាភិបាលដែលមានសកម្មភាពដោយឡែកនិងមិនស្ថិតក្នុងគោលដៅសុទ្ធសាធរបស់ខ្លួន ត្រូវបានចាត់ទុកថាធ្វើសកម្មភាពអាជីវកម្មដោយឡែក ដែលត្រូវចុះបញ្ជីនិងត្រូវជាប់ពន្ធតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។ ហេតុដូចនេះ អគ្គនាយកដ្ឋានពន្ធដារសូមធ្វើការណែនាំដល់សមាគមឬអង្គការមិនមែនរដ្ឋាភិបាលដែលមានសកម្មភាពអាជីវកម្មដោយឡែក ដូចតទៅ÷

### ១- ការចុះបញ្ជីចំពោះសកម្មភាពអាជីវកម្មដោយឡែក

សមាគម និងអង្គការមិនមែនរដ្ឋាភិបាលទាំងឡាយណាដែលមានសកម្មភាពអាជីវកម្មដោយឡែក ត្រូវបានចាត់ទុកជាសហគ្រាសឯកបុគ្គល និងត្រូវចុះបញ្ជីពន្ធដារនៅរដ្ឋបាលសារពើពន្ធ ក្នុងអំឡុងពេល ១៥ថ្ងៃក្រោយពីមានសកម្មភាពអាជីវកម្មទៅតាមកម្រិតផលរបរនិងប្រភេទអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ស្របតាមប្រកាសលេខ ០២៥ សហវ.ប្រក. អពដ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស និងបង់ពន្ធប៉ាតង់ ស្របតាមប្រកាសលេខ ១៩៨ សហវ.ប្រក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការកែសម្រួលវិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ សម្រាប់សកម្មភាពអាជីវកម្មដោយឡែក ។

#### ក- ការចុះបញ្ជីជាអ្នកជាប់ពន្ធតូច

សមាគមឬអង្គការមិនមែនរដ្ឋាភិបាល ត្រូវចាត់បុគ្គលណាម្នាក់ជាតំណាង ដើម្បីគ្រប់គ្រងការប្រកបអាជីវកម្មដោយឡែក។ បុគ្គលដែលជាតំណាងត្រូវបំពេញព័ត៌មានក្នុងទម្រង់ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធដោយភ្ជាប់មកជាមួយនូវឯកសារច្បាប់ដើម ឬច្បាប់ថតចម្លងនៃឯកសារទាំងឡាយដែលមានបញ្ជាក់ទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច ដូចខាងក្រោម÷

- លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ការចុះបញ្ជីចេញដោយ ក្រសួង ឬស្ថាប័នពាក់ព័ន្ធ (បើមាន)
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ដែលមានសុពលភាព
- រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ០៣ខែ ដែលមានទំហំ ៣៥ x ៤៥ មីលីម៉ែត្រ និងមានផ្ទៃខាងក្រោយពណ៌ស ចំនួន ០២សន្លឹក ដែលមានការបញ្ជាក់ឈ្មោះម្ចាស់រូបថត និងចុះហត្ថលេខាទទួលខុសត្រូវដោយប្រធានឬអ្នកតំណាងសមាគមឬអង្គការនានា។
- ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម
- លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ



អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និង ម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855) 23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

### ខ- **ការចុះបញ្ជីជាអ្នកជាប់ពន្ធមធ្យម ឬអ្នកជាប់ពន្ធធំ**

សមាគមឬអង្គការមិនមែនរដ្ឋាភិបាល ត្រូវចាត់បុគ្គលណាម្នាក់ជាតំណាង ដើម្បីគ្រប់គ្រងការប្រកបអាជីវកម្មដោយឡែក។ បុគ្គលដែលជាតំណាងត្រូវមកថតរូប ស្កែនម្រាមដៃដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ និងបំពេញព័ត៌មានក្នុងទម្រង់ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធសម្រាប់សកម្មភាពអាជីវកម្មដោយឡែករបស់ខ្លួន ដោយភ្ជាប់មកជាមួយនូវច្បាប់ដើមឬច្បាប់ចម្លងនៃឯកសារពាក់ព័ន្ធទាំងឡាយដោយមានការបញ្ជាក់ទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច ដូចខាងក្រោម÷

- លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ការចុះបញ្ជី ចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ឬ/និង
- លក្ខន្តិកៈរបស់សមាគមឬអង្គការមិនមែនរដ្ឋាភិបាល
- ព័ត៌មានគណនីធនាគារសម្រាប់សកម្មភាពអាជីវកម្មដោយឡែក ដូចជាលិខិតបញ្ជាក់ គណនីធនាគារ របាយ-ការណ៍ធនាគារ ឬសៀវភៅគណនី ដែលចេញដោយធនាគារ
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ដែលមានសុពលភាព
- រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ០៣ខែ ដែលមានទំហំ ៣៥ x ៤៥ មីលីម៉ែត្រ និងមានផ្ទៃខាងក្រោយពណ៌ស ចំនួន ០២សន្លឹក ដែលមានការបញ្ជាក់ឈ្មោះម្ចាស់រូបថត និងចុះហត្ថលេខាទទួលខុសត្រូវដោយប្រធាន ឬអ្នកតំណាងសមាគមឬអង្គការនានា
- ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម
- លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ

## ២- **កិច្ចបញ្ជិកាគណនេយ្យ**

សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលទាំងឡាយណាដែលមានសកម្មភាពអាជីវកម្មដោយឡែក ត្រូវ÷

១- ញែកដាច់ពីគ្នារវាង ដើមទុនវិនិយោគ ទ្រព្យសកម្ម ទ្រព្យអកម្ម បុគ្គលិក-កម្មករ អ្នកគ្រប់គ្រង និងព័ត៌មានហិរញ្ញវត្ថុផ្សេងៗដែលសម្រាប់បម្រើឱ្យសមាគមឬអង្គការមិនមែនរដ្ឋាភិបាល និងដែលសម្រាប់បម្រើឱ្យសកម្មភាពអាជីវកម្មដោយឡែក។

២- អនុវត្តវិធាននិងគោលការណ៍នៃបញ្ជីគណនេយ្យសាមញ្ញស្របតាមប្រកាសលេខ ១៨២០ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការកំណត់វិធាននិងនីតិវិធីនៃការអនុវត្តបញ្ជីគណនេយ្យសាមញ្ញសម្រាប់អ្នកជាប់ពន្ធតូច។

៣- អនុវត្តវិធានគណនេយ្យតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ស្របតាមបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូលសម្រាប់អ្នកជាប់ពន្ធមធ្យម ឬអ្នកជាប់ពន្ធធំ។

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមយ៉ាងមុតមាំថា គ្រប់សមាគមឬអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា នឹងយកចិត្តទុកដាក់ចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះប្រកបដោយប្រសិទ្ធភាព។

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

គង់ វិបុល